# FMO

**Finance for Development**

ឈានដល់កម្រិតថ្មី សន្និសីទកំពូលស្តីពីមីក្រូហិរញ្ញវត្ថុ ឆ្នាំ ២០០៧

លទ្ធភាពទទួលសេវាហិរញ្ញវត្ថុកាន់តែប្រសើរឡើង

ថ្ងៃទី ២៩-៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សណ្ឋាគារកាំបូឌីយ៉ាណា

បទបង្ហាញរបស់វិនិយោគិនៈ ថ្ងៃ សុក្រ ទី ៣០ ខែ វិច្ឆិកា ម៉ោង ១៣:៣០ - ១៤:៣០

# FMO

FMO វិនិយោគទុនមានហានិភ័យនៅក្នុងក្រុមហ៊ុនផ្នែកឯកជននិងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ គោលបំណងគឺដើម្បីបង្កើតសហគ្រាសរីកលូតលាស់ដែលអាចបម្រើជាក្បាលម៉ាស៊ីននៃកំណើនប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសរបស់ក្រុមហ៊ុនទាំងនោះ ។

ម្ចាស់ភាគហ៊ុនៈ រដ្ឋាភិបាលហូឡង់ ៥១% ធនាគារពាណិជ្ជនិងភាគីផ្នែកឯកជនផ្សេងទៀត ៤៩% ។ ចំណាត់ថ្នាក់ AAA ។ នាំមុខដោយទីផ្សារ ។

បំពេញបន្ថែមលើធនាគារពាណិជ្ជ ។ ប្រសិនបើទីផ្សារចាត់ចែងៈ នោះ មាន FMO ។

ផលិតផលៈ ឥណទាន (LCY និង ដុល្លារ/អឺរ៉ូ) syndications ការធានា mezzanine ផលិតផលទុន ។ ទំនាក់ទំនងរយៈពេលវែងជានិច្ច ។

ចំនួនសន្យាៈ ២.៧00 លានអឺរ៉ូៈ (អាហ្វ្រិក ២១% អាស៊ី ២១% អាមេរិកឡាទីន ២៩% អឺរ៉ុបខាងកើត/អាស៊ីកណ្ដាល ២៩%) ។

សេវាកម្មៈ អភិវឌ្ឍន៍សមត្ថភាព ជួយគាំទ្របរិស្ថាននិងសង្គម ជួយគាំទ្រអភិបាលកិច្ចសាជីវកម្ម

វិស័យៈ ហិរញ្ញវត្ថុ ៥៦% ហេដ្ឋារចនាសម្ព័ន្ធ ២0% ឧស្សាហកម្ម/ពាណិជ្ជកម្ម ១៩% ផ្សេងៗ ៥%

# FMO

ក- តើមូលហេតុអ្វីដែល FMO បានវិនិយោគលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា?

១- កម្ពុជា/តំបន់មេគង្គត្រូវបានជ្រើសរើសជាយុទ្ធសាស្ត្រដើម្បីឱ្យមានតួនាទីធំនៅក្នុងការធ្វើឱ្យវិស័យមីក្រូហិរញ្ញវត្ថុឈានដល់កម្រិតមួយខ្ពស់ជាង ជាមួយនឹងទិសដៅពង្រីងនិងធនាគារថ្មី ។

២- ធនាគារជាតិនៃកម្ពុជាបានបង្កើតហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរឹងមាំ និង មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអភិបាលកិច្ចសាជីវកម្មសមរម្យរឹងមាំដ៏សំខាន់ ការគ្រប់គ្រងសមស្រប និង សក្តានុពលសម្រាប់កំណើនសម្រាប់ការចងជាដៃគូជាមួយ ។

៣- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហិរញ្ញវត្ថុទាំងនេះត្រូវការទុន និង/ឬ ការផ្តល់មូលនិធិរយៈពេលវែងជាប្រាក់រៀលឬដុល្លារអាមេរិក ។ ការទាក់ទាញការផ្តល់មូលនិធិនេះនៅក្នុងទីផ្សារក្នុងស្រុកគឺមានការលំបាក ។

៤- ធ្វើ រំពឹងថាឥណទានទាំងនេះ (តាមអត្រាទីផ្សារ) នឹងត្រូវបានសង ហើយទុនដែលមាននឹងផ្តល់ផលចំណេញ ។

# FMO

ខ- តើគោលដៅរបស់ FMO ត្រូវបានសម្រេចឬទេ? (តើសមិទ្ធផលនេះត្រូវបានវាស់ដូចម្តេច?)

១- យើងមានឥណទានមិនទាន់ទូទាត់ជាមួយធនាគារ ACELEDA, AMRET, CEB, PRASAC, TPC និង ភាគហ៊ុននៅក្នុងធនាគារ ACELDA, CEB, PRASAC ។ ការបន្តកិច្ចព្រមព្រៀងកំពុងពិភាក្សាគ្នា ។ ឥទណទានបច្ចុប្បន្នមានទឹកប្រាក់ចំនួន ៣៣ លាន ដុល្លារអាមេរិក ។ ទិសដៅចុងឆ្នាំ ២០០៨៖ ទឹកប្រាក់ចំនួន ៥០ លាន ដុល្លារអាមេរិក ។

២- អតិថិជនរបស់យើងមានហិរញ្ញវត្ថុគន្លឹះនិងកំណើនរឹងមាំ ហើយយើងបើកចំហរដើម្បីកែលម្អអភិបាលកិច្ចសាជីវកម្ម លើកស្ទួយការយល់ដឹងអំពីហានិភ័យអំពីបញ្ហាបរិស្ថាននិងសង្គមកិច្ច និង កែលម្អគុណភាពនៃការគ្រប់គ្រង ។ FMO ដឹកនាំដោយតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល និង ផ្តល់មូលនិធិអភិវឌ្ឍន៍សមត្ថភាព ។

៣- កាតព្វកិច្ចសងឥណទានជាមួយនឹងអត្រាការប្រាក់ផ្សារភ្ជាប់ទីផ្សារ (AWDR + ចំណេញ) មកដល់ពេលនេះគឺបានសម្រេច ។ ចំណូលភាគលាភពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺនៅទាប ។ FMO មិនទាន់មានបទពិសោធន៍ពាក់ព័ន្ធនឹងការថយចេញនៅកម្ពុជាទេ ។

# FMO

គ- តើ FMO នឹងបន្តនៅជាវិនិយោគិនទុននៅក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្រោយពេល ៥ ឆ្នាំ ឬទេ និង តើ FMO មើលឃើញតួនាទីរបស់ខ្លួននៅក្នុងការអភិវឌ្ឍន៍បន្ថែមទៀតនៃវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យ៉ាងដូចម្តេច?

មែនហើយ

ជាធម្មតា FMO គឺជាម្ចាស់ភាគហ៊ុនសម្រាប់រយៈពេលយ៉ាងតិចបំផុតពី ៥ ទៅ ៧ ឆ្នាំ ប្រសិនបើ គេមិនត្រូវឃើងទៀតទេ ឬ មួយយើងមិនបានបង្កើតតម្លៃបន្ថែមតទៅទៀត។ យើងនឹងលក់ ភាគហ៊ុនជូនភាគីផ្សេកឯកជន ជាពិសេសដៃគូជាយុទ្ធសាស្ត្រដែលធានាការអភិវឌ្ឍន៍ជាបន្ត។

# FMO

ឃ- តើ FMO មានគំនិតដូចម្តេចអំពីការចាកចេញជាម្ចាស់ភាគហ៊ុនមួយនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង តើអ្នកយល់យ៉ាងដូចម្តេចអំពីកិច្ចអភិវឌ្ឍន៍វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា?

- វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពេលនេះគឺមានពិពិធភាពច្រើនពេក ខ្វះទុន និងពឹងផ្អែកលើអ្នកផ្តល់ជំនួយ / ការផ្តល់មូលនិធិពីវិនិយោគផ្ទាល់បរទេស ដែលរារាំងដល់ការរីកលូតលាស់បន្ថែមទៀត ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគប្បីបំពេញតួនាទីកាន់តែសកម្មនៅក្នុងការទាក់ទាញប្រាក់បញ្ញើ ។

- FMO យល់ឃើញថាមានលទ្ធភាពច្រើនសម្រាប់ការពង្រឹង ។ FMO នឹងគាំទ្រនិងផ្តួចផ្តើមគោលនយោបាយដ៏សកម្មមួយ ដែលនៅក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងរួមបញ្ចូលគ្នា ទិញគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងបង្កើនកម្រិតឡើងដល់កម្រិតធនាគារ ។

- ក្រោយប្រការនេះត្រូវបានសម្រេចបាន FMO នឹងលក់ភាគហ៊ុនរបស់ខ្លួនជូនដល់វិនិយោគិនផ្នែកឯកជនពិតប្រាកដ ។ នៅពេលនោះ ឥណទាន/ផលិតផលថ្មី ។ល។ នឹងត្រូវបានផ្តល់តែប្រសិនបើប្រការនេះជួយលើកស្ទួយវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យបានដល់កម្រិតមួយខ្ពស់ជាងប៉ុណ្ណោះ ។ ផលិតផលគប្បីដាក់ឱ្យប្រើ និងគាំទ្រគំនិតផ្តួចផ្តើមថ្មីៗ ( មូលប័ត្រ សញ្ញាប័ណ្ណ ភតិសន្យា ហិរញ្ញប្បទានផ្ទះ ។ល។)